ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៥
ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

សាលដីកា

លេខ ៥៧ "III"
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៧១ "ក្រ.VII.ភ.ស" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ** ៖ ជនត្រូវចោទឈ្មោះ [redacted] ចំរើន ភេទប្រុស ឆ្នាំកំណើត ១៩៨៤ ជនជាតិខ្មែរ មានមុខរបរលក់ម៉ូតូ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តរតនគិរី។

-មានលោកមេធាវី [redacted] ផានិត ជាអ្នកការពារ ។

Scanned with CamScanner

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមពីបទ ប្រឆាំងនឹងអ្នករាជការសាធារណៈ និងធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅភូមិជ័យជម្នះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥០៣ , មាត្រា ៥០៤ និងមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ ។

<u>អំពីអង្គហេតុ៖</u>

កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ តុលាការបានធ្វើការចុះអនុវត្តដីកាសម្រេចរក្សាការពារលេខ ០១ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ ដែលបានសម្រេចមិនឱ្យធ្វើសកម្មភាពសាងសង់សំណង់លើដីដែលមានទំនាស់របស់ឈ្មោះ [redacted] សុខអូន និងឈ្មោះ [redacted] ចំរើន ក៏ប៉ុន្តែរយៈពេល ៤ ថ្ងៃក្រោយការចុះអនុវត្ត ម្ចាស់សំណង់ឈ្មោះ [redacted] សុខអូន និងឈ្មោះ [redacted] ចំរើន នៅតែបានបន្តជួលក្រុមជាងឈ្មោះ [redacted] គាត់ ជាមេជាងនិងឈ្មោះ [redacted] ហេង នៅតែបន្តការសាងសង់សំណង់លើដីមានទំនាស់ដដែល ដោយសម្រេចបានប្រហែលជា ៩0% នៃសំណង់ ។ ឃើញដូចនេះ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ តុលាការក៏បានចុះបន្តត្រួតពិនិត្យនិងអនុវត្តផ្អាកការសាងសង់ ។ ក៏ប៉ុន្តែម្ចាស់សំណង់ឈ្មោះ [redacted] សុខអូន និងឈ្មោះ [redacted] ចំរើន មិនបានសហការជាមួយនឹងមន្ត្រីតុលាការនិងអាជ្ញាធរមានសមត្ថកិច្ចនោះទេ មិនត្រឹមតែប៉ុណ្ណោះបានប្រើហិង្សាប្រឆាំងតបតវិញ ដោយធ្វើសកម្មភាពផ្សាយផ្ទាល់វីដេអូ (live) ព្រមជាមួយនិងពាក្យជេរប្រមាថចំពោះមន្ត្រីតុលាការនិងមន្ត្រីអាជ្ញាធរដែលចុះអនុវត្តដីកាសម្រេចរបស់តុលាការ។

-បានឃើញ ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ៧១១/១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តរតនគិរី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖ <u>*"មិនឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន (មានអត្តសញ្ញាណដូចខាងលើ) ជាបណ្តោះអាសន្នឡើយ"*</u> ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់លោកព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តរតនគិរី ប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ៧១១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តរតនគិរី ត្រង់ចំណុចដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន។

សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៧១ "ក្រ.VII.ភ.ស" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តរតនគិរី ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

Scanned with CamScanner

២-បដិសេធដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ៧១១/១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តរតនគិរីចោលជាអសារបង់ ។

៣-សម្រេចឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ៣៦ ឆ្នាំ (មានសាវតាជាតិខាងលើ) ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទប្រឆាំងនឹងអ្នករាជការសាធារណៈ និងធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅចំណុចភូមិជ័យជម្នះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥០៣ មាត្រា ៥០៤ និងមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ ។

៤-បង្គាប់មកអាជ្ញាធរមានសមត្ថកិច្ចឱ្យស្វែងរកចាប់ខ្លួននិងឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ៣៦ ឆ្នាំ (មានសាវតាជាតិខាងលើ) មកឃុំទុកនៅមណ្ឌលឃុំខ្លួន ឬពន្ធនាគារខេត្តរតនគិរី តាមនីតិវិធីច្បាប់ ។

សាលដីកានេះ ពិភាក្សាសួរដេញដោលជាអសាធារណៈ នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន ក្នុងការប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៧១ "ក្រ.VII.ភ.ស" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

### នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលបានបដិសេធដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នរបស់សាលាដំបូង និងបានសម្រេចឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន ពីបទប្រឆាំងនឹងអ្នករាជការសាធារណៈ និងបទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ បង្គាប់ឱ្យអាជ្ញាធរមានសមត្ថកិច្ចស្វែងរកចាប់ខ្លួននិងឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន នោះ គឺមានសំអាងហេតុត្រឹមត្រូវតាមច្បាប់ ព្រោះថា ជនត្រូវចោទបានប្រព្រឹត្តអំពើដូចមានក្នុងសំអាងហេតុត្រង់ចំណុចទី២ ,ទី៣ និងទី៤ នៃសាលដីការបស់សាលាឧទ្ធរណ៍ ។

-ជនត្រូវចោទឈ្មោះ [redacted] ចំរើន បានឆ្លើយថា សុំប្រគល់សិទ្ធិឱ្យលោកមេធាវីជាអ្នកបកស្រាយ។



Scanned with CamScanner

-លោកមេធាវី [redacted] ផានិត ជាអ្នកការពារបានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនសូមបញ្ជាក់ថាទំនាស់រឿងតិចតួចដែលមានការដាក់អីវ៉ាន់ប៉ះពាល់ទៅលើម្ចាស់របស់ភាគីម្ខាងទៀត ដែលបង្កជាទំនាស់ឡើង ហើយភាគីម្ខាងដាក់រក្សាការពារដើម្បីកុំឱ្យជនជាប់ចោទធ្វើសកម្មភាពបន្តទៀត។ តែនៅពេលដែលរក្សាការពារចេញមកបានចុះអនុវត្តហើយ ដល់ថ្ងៃក្រោយមកភាគីម្ខាងក៏នៅតែបន្តធ្វើដោយដាក់អីវ៉ាន់ប៉ះពាល់លើអ្នកជិតខាងតែប៉ុណ្ណោះនេះពិនិត្យលើរឿងអង្គសេចក្តី ។ ចំណុចនេះឃើញថា ទាក់ទងនឹងបទចោទមិនដឹងថារឿងអង្គសេចក្តី មិនដឹងថាតើអ្នកណាជានាក់ដាក់ ឬខាងព្រះរាជអាជ្ញារងប្តឹងចោទតែម្តង ឬដើមបណ្តឹងរដ្ឋប្បវេណីមានទំនាស់ក្នុងរឿងស៊ីវិលប្តឹង? ប៉ុន្តែមកទល់ពេលនេះឃើញថា ភាគីទាំងពីរបានព្រមព្រៀងគ្នាហើយ មានន័យថាដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទបានព្រមព្រៀងគ្នាដកពាក្យបណ្តឹងហើយ ប៉ុន្តែនៅបណ្តឹងអាជ្ញា ។ ខ្លួនសូមធ្វើការកត់សម្គាល់ថា សូមធ្វើការឯកភាពលើសេចក្តីសម្រេចរបស់សាលាដំបូងខេត្តរតនគិរី ចៅក្រមស៊ើបសួរដែលសម្រេចមិនឃុំខ្លួន ហើយសម្រេចឱ្យជនត្រូវចោទនៅក្រៅឃុំ ហើយចេញលក្ខខណ្ឌដើម្បីឱ្យជនត្រូវចោទគោរពតាម ដូចជាដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ យោងតាមមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្នលុះណាទាល់តែមានភាពចាំបាច់។ ហើយមាត្រា ២០៥ ភាពចាំបាច់មួយចំនួន តើជនត្រូវចោទបានបង្កើតបទល្មើសជាថ្មីទៀតដែរឬទេ ជៀសវាងធ្វើឱ្យអសន្តិសុខ បទល្មើសនេះជាបទល្មើសមួយដែលព្រះរាជអាជ្ញាចោទពីបទមជ្ឈឹមដែលប្រឆាំងនឹងមន្ត្រីសាធារណៈ ការមិនព្រមអនុវត្តលើដីកាសម្រេចរបស់តុលាការ ប៉ុន្តែតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានសម្រេចថា ការឃុំខ្លួននេះដើម្បីយកទៅអនុវត្តលើដីកាសម្រេច ប៉ុន្តែភាគីនេះបានឯកភាពព្រមព្រៀងគ្នារួចហើយ មានន័យថា ជនជនត្រូវចោទយល់ព្រមទៅលើដីការក្សាការពារហើយ ហើយភាគីដែលសុំរក្សាការពារបានសុំដកគម្លាតរក្សាការពារនេះដែរ ។ ខ្លួនជាមេធាវីយល់ឃើញថា ការសម្រេចរបស់ចៅក្រមស៊ើបសួរសាលាដំបូងសម្រេចមិនឃុំខ្លួនជាការត្រឹមត្រូវ ។

<u>សំណូមពរ</u>៖ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះបដិសេធសាលដីកាលេខ ៧១ “ក្រVII.ភ.ស” ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ចោលជាអសាបង់ ហើយសម្រេចឱ្យជនត្រូវចោទនៅក្រៅឃុំ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានបន្ថែមថា ខ្លួនសុំឯកភាពជាមួយនឹងមេធាវីដែលបានលើកឡើងដែលថា គូភាគីបានព្រមព្រៀងគ្នា ។ ចំពោះដីការក្សាការពារបានដក ហើយក៏លែងមានអានុភាពទៀតហើយ ។

Scanned with CamScanner

-ក្រោយពីបានស្ដាប់សេចក្ដីរាយការណ៍របស់ចៅក្រមរបាយការណ៍
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនត្រូវចោទ
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីឱ្យជនត្រូវចោទ
-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

**តុលាការកំពូល**

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចំរើន ប្រឆាំងនឹងសាលដីកាលេខ ៧១ "ក្រVII.ភ.ស" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា៤១៨ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] ចំរើន បានធ្វើកិច្ចសន្យាព្រមព្រៀងគ្នា ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ជាមួយនឹងភាគី [redacted] លឿ ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ ដោយឈ្មោះ [redacted] ចំរើន សុខចិត្តសងប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក ទៅឱ្យឈ្មោះ [redacted] លឿ ។ ឯឈ្មោះ [redacted] លឿ ក៏សុខចិត្តដកពាក្យបណ្ដឹងរបស់ខ្លួនក្នុងសំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ និងបានសុំដករួចហើយដែរ។ ម្យ៉ាងទៀតគូភាគីទំនាស់ក្នុងរឿងក្ដីនេះជាអ្នករស់នៅផ្ទះជាប់របងគ្នាផង ដែលជាមូលហេតុមួយអាចឱ្យតុលាការកំពូលពិចារណាថា ការចាប់ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន ជាបណ្ដោះអាសន្នមុនការជំនុំជម្រះរឿងក្ដីលើរូបគាត់លែងមានភាពចាំបាច់ និងលែងសមស្របទៀតហើយ។

៣-យល់ឃើញថា មេធាវីការពារក្ដីឱជនត្រូវចោទបានធ្វើសេចក្ដីសន្និដ្ឋាន និងបង្ហាញពីជំហររបស់ខ្លួនដោយសុំគាំទ្រដីកាសម្រេចមិនឃុំខ្លួនលេខ ២៥៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តរតនគិរី ។ ដោយសារតែជនត្រូវចោទត្រូវបានគោរពនិងអនុវត្តបាននូវលក្ខខណ្ឌមួយចំនួនដែលចៅក្រមស៊ើបសួរបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការរួចមក ។ ម្យ៉ាងទៀត ចៅក្រមស៊ើបសួររបស់សាលាដំបូងខេត្តរតនគិរីបានចេញដីកាដំណោះស្រាយលេខ ១១/២០ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ និងបានបញ្ជូនដីកាដំណោះស្រាយព្រមទាំងសំណុំរឿងអង្គសេចក្ដីទៅតុលាការសាលាដំបូងខេត្តរតនគិរី ដើម្បីចាត់ការជំនុំជម្រះរួចហើយដែរ។ ដូចនេះ ការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន យោងតាមបទប្បញ្ញត្តិមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ លែងមានភាពចាំបាច់ទៀតហើយ គឺសេចក្ដីសន្និដ្ឋានមានមូលដ្ឋានសមស្របទាំងអង្គហេតុ ទាំងអង្គច្បាប់ ។

៤-យល់ឃើញថា សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ របស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា បណ្ដឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី២៩ ខែវិច្ឆិកា



Scanned with CamScanner

ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចំរើន ធ្វើឡើងក្នុងកំណត់ច្បាប់ ។ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលបានសម្រេចបដិសេធដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នរបស់សាលាដំបូងខេត្តរតនគិរី និងបានសម្រេចឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន ពីបទប្រឆាំងនឹងអ្នករាជការសាធារណៈ និងធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ។ បង្គាប់ឱ្យអាជ្ញាធរមានសមត្ថកិច្ចស្វែងរកចាប់ខ្លួននិងឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ចំរើន នោះ គឺមានសំអាងហេតុត្រឹមត្រូវតាមច្បាប់ ដោយហេតុថា ជនត្រូវចោទបានប្រព្រឹត្តអំពើដូចមានក្នុងសំអាងហេតុត្រង់ចំណុចទី២, ទី៣ និងទី៤ នៃសាលដីការបស់សាលាឧទ្ធរណ៍នោះលែងមានភាពសំខាន់ចាំបាច់តទៅទៀតហើយ ដោយមានមូលហេតុដូចតុលាការកំពូលបានលើកបង្ហាញក្នុងផ្នែកសំអាងហេតុដូចខាងលើត្រង់ចំណុចទី២ និងទី៣ រួចហើយ ។

៥-យល់ឃើញថា នាពេលសវនាការ តំណាងមហាអយ្យការ ក្រោយពីបានធ្វើសេចក្តីសន្និដ្ឋានការពារសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សររបស់ខ្លួន ដូចមានខ្លឹមសារនៃសេចក្តីសេចក្តីសន្និដ្ឋានដែលតុលាការកំពូលបានលើកបង្ហាញនៅផ្នែកសំអាងហេតុត្រង់ចំណុចទី៤ ខាងលើនេះ និងក្រោយពីបានស្តាប់ការលើកឡើងបង្ហាញនូវឯកសារ ភស្តុតាងសំខាន់ៗ ដែលពាក់ព័ន្ធរបស់ជនត្រូវចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនត្រូវចោទរួចមក បានធ្វើការកត់សម្គាល់ថា ខ្លួនឯកភាពនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តរតនៈគិរីដែលសម្រេចមិនឃុំខ្លួនជនត្រូវចោទ ជាសេចក្តីសន្និដ្ឋានសមស្របទៅនឹងស្ថានភាពវិវត្តនិងដំណាក់ជាក់ស្តែងនៃនីតិវិធីក្នុងចំណាត់ការរឿងក្តីព្រហ្មទណ្ឌ និងស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៧១ "ក្រVII.ភ.ស" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្តីមកនេះលែងសមស្របនឹងកាលៈទេសៈ និងគតិច្បាប់ទៀតហើយ ។

៧-យល់ឃើញថា ដោយមានសំអាងហេតុដូចលើកបង្ហាញខាងលើនេះ ដូច្នេះ ដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនលេខ ៥០ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញនឹងអស់អានុភាពអនុវត្តហើយ ដែលតុលាការកំពូលគប្បីត្រូវសម្រេចរំលត់អានុភាពដីកានេះ ។

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១-ឧទ្ធរណ៍ពាក្យបណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចំរើន ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-បដិសេធសាលដីកាលេខ ៧១ "ក្រVII.ភ.ស" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ។



Scanned with CamScanner

៣-រំលត់អានុភាពដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនលេខ ៥០ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃចន្ទ ទី០២ ខែមីនា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃចន្ទ ទី០៩ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner